ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន

លេខ ៣៦១/១១ [illegible] អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ កញ្ញា ឆ្នាំ ២០១១
## និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ តុលា ឆ្នាំ ២០១១

(០១/០៩/២០១១-២៥/០៩/២០១១)

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលសម្រេចបាននៅក្នុងខែកញ្ញា ឆ្នាំ២០១១នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែកញ្ញាឆ្នាំ២០១១នេះ ពួកឈ្មួញគ្រឿងញៀនក្នុងតំបន់ នៅតែបន្តនាំគ្រឿងញៀនសំយោគប្រភេទមេតំហ្វេតាមីនគ្រាប់ (WY) និង មេតំហ្វេតាមីនទឹកកក (ICE) ពីតំបន់ព្រំដែននៃបណ្តាខេត្តនៅភាគឦសានចូលមកក្នុងប្រទេស ជាក់ស្តែង យើងបានរកឃើញពួកឈ្មួញគ្រឿងញៀននៃប្រទេសជិតខាងចំនួន ២ ករណី (២ក្រុម) ដែលបានធ្វើសកម្មភាពនាំគ្រឿងញៀនចូលមកកម្ពុជា ។ នៅទិសពាយ័ព្យ តាមរយៈការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ភាគីថៃបានឱ្យដឹងថា សមត្ថកិច្ចច្រកព្រំដែន A/05 ស្រុកអារញ្ញ ខេត្តស្រះកែវ បានឃាត់ខ្លួនជនជាតិខ្មែរ ១ នាក់ កាលពីថ្ងៃ១៣ ខែកក្កដា ឆ្នាំ២០១១ ពីបទជួញដូរគ្រឿងញៀនមេតំហ្វេតាមីន (WY) ចំនួន ៥.៩៦០ គ្រាប់ និង មេតំហ្វេតាមីនទឹកកក (ICE) ចំនួន ៩៩,៨៥ ក្រាម ។

ដោយឡែក ក្រុមស៊ីឈ្នួលរត់ពន្ធគ្រឿងញៀនឱ្យពួកឧក្រិដ្ឋជន **អាហ្វ្រិកខាងលិច** ក៏បានបន្តការទាក់ទងតាមគ្រប់វិធីដើម្បីនាំគ្រឿងញៀនចេញពីកម្ពុជាទៅក្រៅប្រទេស ជាក់ស្តែង កន្លងមកនេះសមត្ថកិច្ចបង្ក្រាបបាន ២ ករណី ។ ក្រៅពីចំណុចកត់សំគាល់ខាងលើ អនុវត្តតាម "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" សមត្ថកិច្ចបានបន្តការបោសសំអាតបទល្មើសជួញដូរ និង ប្រើប្រាស់គ្រឿងញៀនតូចតាចជាច្រើនកន្លែងដែលកើតឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ធ្វើឱ្យបទល្មើសគ្រឿងញៀននៅក្នុងខែកញ្ញានេះ មានការថយចុះបើប្រៀបធៀបទៅនឹងខែសីហាកន្លងទៅ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ខែកញ្ញានេះ យើងបានកត់សំគាល់ឃើញមានសកម្មភាពសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល សម្រាប់ជាគោលការណ៍ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

- សារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ផ្ញើជូនបងប្អូនជនរួមជាតិ ជាពិសេសក្មួយៗជាសិស្សានុសិស្ស នៅក្នុងទិវាអក្ខរកម្មជាតិ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ក្រោមប្រធានបទ "**អក្ខរកម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន**" ។
- ការចេញអនុក្រឹត្យ លេខ ១៩១ អនក្រ-បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពី**មន្ត្រីទទួលទោសទៅក្រោមសហការណ៍**ដែលមាត្រា ១៤ នៃអនុក្រឹត្យនេះ **ក្នុងចំណុច (ឆ)** បានចែងច្បាស់ពីភាតព្វកិច្ចរបស់មន្ត្រីទទួលទោសទៅក្រោមសហការណ៍ថា "ប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ ដែលនៅជិតបំផុតក្នុងករណីដឹង ឬ មានការសង្ស័យថា មានការប្រព្រឹត្តបទល្មើស ការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និងណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន (សកម្មភាពលំអិតមាននៅក្នុងតារាងឧបសម្ព័ន្ធ) ហើយផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អគ្គលេខាធិការដ្ឋាន បានអនុវត្តសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម :

### *១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័នជាសមាជិក, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានបន្តយកចិត្តទុកដាក់លើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង គ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាពដូចខាងក្រោម :

#### *១.១. សកម្មភាពអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ*

តាមរយៈកិច្ចសហការសម្របសម្រួលជាមួយ **ក្រសួងព័ត៌មាន, ក្រសួងធម្មការ និងសាសនា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** យើងបានស្នើសុំឱ្យ :

- ស្ថានីយទូរទស្សន៍ CTN ផ្សព្វផ្សាយនូវរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងរយៈពេល ៨ខែ ឆ្នាំ២០១១ ។
- ស្ថានីយទូរទស្សន៍ CTN ម៉ាយធីវី ដើម្បីជួយបង្កើនការចាក់ផ្សាយឱ្យបានច្រើនដងថែមទៀតនូវបទចម្រៀងទាំងឡាយណា ដែលមានបង្កប់ន័យអប់រំដល់យុវជនកុំឱ្យប្រើគ្រឿងញៀន ។
- ក្រុមសិល្បករ ពិធីករ តន្ត្រីករ តាមបណ្តាស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋ និង ឯកជន បានបង្កើនសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

- គ្រប់បណ្តាញស្ថានីយទូរទស្សន៍រដ្ឋ និង ឯកជន បានបន្តការផ្សព្វផ្សាយ ស្ព័ត អប់រំបង្ការការប្រើប្រាស់គ្រឿងញៀន តាមរយៈកម្មវិធីសន្តិសុខមាតុភូមិរបស់ក្រសួងមហាផ្ទៃ និងកម្មវិធីប្រចាំថ្ងៃរបស់ ស្ថានីយទូរទស្សន៍នានា ។
- **ក្រសួងកិច្ចការនារី** បានបន្តជំរុញការផ្សព្វផ្សាយអប់រំ ស្តីពីអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងសារសំខាន់ៗពាក់ពន្ធ័នឹងការបង្ការទប់ស្កាត់គ្រឿងញៀន តាមវិទ្យុនិងទូរទស្សន៍ ។
- **ក្រសួងធម្មការនិងសាសនា** បានបន្តការអនុវត្តកម្មវិធី ព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម ដើម្បីលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហឹង្សា ។
- **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** បានបន្តណែនាំដល់ផលិតកម្មភាពយន្ត-វីដេអូ និងក្រុមហ៊ុន នាំចូល នាំចេញ ខ្សែភាពយន្ត-វីដេអូ ឱ្យដាក់ **សារ** អប់រំពីគ្រឿងញៀន នៅលើផលិតផលនៃផលិតកម្មរបស់ខ្លួន ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានអញ្ជើញ **គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ** ផ្តល់នូវកិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN ក្រោមប្រធានបទស្តីពី ការទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តបន្ទាយមានជ័យ ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន (ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១) ។

### ***១.២. សកម្មភាពផ្សព្វផ្សាយអប់រំផ្ទាល់***

សកម្មភាពផ្សព្វផ្សាយអប់រំផ្ទាល់នេះ តាមរយៈ **ក្រសួងអប់រំយុវជននិងកីឡា, ក្រសួងទេសចរណ៍, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម** យើងបានបន្ត អនុវត្តកម្មវិធីដូចតទៅ :

- **ក្រសួងអប់រំយុវជន និងកីឡា** បានណែនាំឱ្យមន្ទីរអប់រំយុវជននិងកីឡារាជធានី-ខេត្ត ប្រារព្ធទិវាអក្ខរកម្មជាតិ ថ្ងៃទី ០៨ខែកញ្ញាឆ្នាំ២០១១ ក្រោម ប្រធានបទស្តីពី "អក្ខរកម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន" ។
- បានរៀបចំកិច្ចប្រជុំតុមូលនៅក្រសួងអប់រំយុវជន និងកីឡា ក្នុងន័យបំផុសចលនាអក្ខរកម្មឱ្យបានជ្រួតជ្រាបគ្រប់ក្រសួង-ស្ថាប័នរដ្ឋ និង ឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ដែលឆ្នាំនេះ ក្រសួងបានកំណត់យកប្រធានបទស្តីពី **អក្ខរកម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន** ។
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿង ញៀន(ICHAD) ។ លទ្ធផលដែលត្រូវបានកត់សំគាល់គឺ ក្រៅពីការបញ្ជ្រាបបញ្ហាគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សា **ថ្នាក់ទី៦ ថ្នាក់ទី៩ ថ្នាក់ទី១១** ក្នុងមុខវិជ្ជាដែលក្រសួងអប់រំយុវជននិងកីឡា យល់ឃើញថាអាចជាប់ពាក់ពន្ធ័ទៅនឹងបញ្ហាគ្រឿងញៀន ក្រសួងបានដាក់បញ្ចូលការអប់រំពីគ្រឿងញៀនផ្ទាល់ទៅក្នុងសៀវភៅកម្មវិធីសិក្សា ដោយមានចំនួនម៉ោងជាក់លាក់គឺ សម្រាប់ថ្នាក់ទី៨ ស្តីពីទុក្ខទោសដល់រាងកាយនិងការបង្ការការប្រើប្រាស់គ្រឿងញៀន (មានរយៈពេលសិក្សា ១២ ម៉ោងក្នុង ១ឆ្នាំ) និងសម្រាប់ថ្នាក់ទី១១ ស្តីពីគុណវិបត្តិនៃគ្រឿងញៀន (មានរយៈពេលសិក្សា៥ម៉ោងក្នុង១ឆ្នាំ) ។
- **ក្រសួងទេសចរណ៍** បាននិងកំពុងជំរុញដល់មន្ទីរទេសចរណ៍ រាជធានី-ខេត្ត ឱ្យអនុវត្តតាមស្មារតីអនុក្រឹត្យស្តីពី មគ្គុទ្ទេសក៍ទេសចរណ៍ និងបានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឱ្យបិទផ្សាយនូវខិត្តបណ្ណ័ផ្សព្វផ្សាយអំពីគ្រឿងញៀន អេដស៍ ការជួញដូរផ្លូវភេទ និង ការជួញដូរអាវុធជាតិផ្ទុះ នៅតាមគោលដៅសេវាកម្មទេសចរណ៍នានា (ផ្ទះសំណាក់ សណ្ឋាគារ កន្លែងកម្សាន្ត នានា) ។

- **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម** បានបន្តជំរុញវិស័យឯកជនអនុវត្តការបិទ សារ អប់រំពីផលប៉ះពាល់នៃគ្រឿងញៀននៅលើផលិតផលភេសជ្ជៈ ម្ហូបអាហារ និងផលិតផលផ្សេងៗទៀតរបស់ក្រុមហ៊ុនខ្លួន ។

ក្រៅពីសកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់របស់ក្រសួង-ស្ថាប័នខាងលើ គឺនៅមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៦ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន (ដូចមានរាយឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធ) ដែលបានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំជាប្រចាំ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ជារួមនៅក្នុងសកម្មភាពផ្សព្វផ្សាយអប់រំផ្ទាល់ និងសកម្មភាពបណ្តុះបណ្តាលធនធានមនុស្ស ដែលបានធ្វើឡើងដោយក្រសួង-ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង ៦ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន គឺមានអ្នកចូលរួមសរុប **៤.៤៤១** នាក់ ។

## ២. *ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែកញ្ញាឆ្នាំ២០១១នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. *ការបង្ក្រាបបទល្មើសគ្រឿងញៀន*

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៥០** ករណី លើ ៦៦ ករណី ប្រៀបធៀបនឹងខែសីហា ឆ្នាំ២០១១ គឺថយចុះ **២៤,២៤** % ។

**-ឃាត់ខ្លួនជនសង្ស័យ ១៣៥** នាក់ លើ ១៤៨ នាក់ ប្រៀបធៀបនឹងខែសីហាឆ្នាំ២០១១ គឺថយចុះ ៨,៧៨ % ។ ក្នុងនោះ ខ្មែរ១២២នាក់(ស្រី២១នាក់), វៀតណាម៦នាក់(ស្រី១នាក់), ឡាវ៣នាក់(ប្រុស), ថៃ១នាក់(ស្រី) ,ឥណ្ឌា១នាក់(ប្រុស), នីហ្សេរីយ៉ា២នាក់(ប្រុស) បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។

**-វត្ថុតាងចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ WY ២.០០០ គ្រាប់, មេតំហ្វេតាមីនទឹកកក(Ice) ១.២៤៩, ១៣២ ក្រាម, កញ្ឆាក្រៀម ១៤,៤៦ ក្រាម និងវត្ថុតាងរួមផ្សំមួយចំនួនទៀត ដូចមានរាយក្នុងតារាងឧបសម្ព័ន្ធ ។

### ២.២. *ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង*

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងក្នុងខែកញ្ញានេះ បានចំនួន ១៥៣ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** មាន **០៥ សំណាក = ០៣ %** និងសំណាក **វិជ្ជមានសារធាតុញៀន ១៤៨ សំណាក = ៩៧ %** ក្នុងនោះ ៖

-មេតំហ្វេតាមីនទឹកកក (Ice) ៧៦ សំណាក = ៥០ %
-មេតំហ្វេតាមីនគ្រាប់ ៦១ សំណាក = ៤០ %
-កញ្ឆាក្រៀម ២ សំណាក = ១ %
-កេតាមីន ៥ សំណាក = ៣ %
-ហេរ៉ូអ៊ីន ៣ សំណាក = ២ %
-ប្រូហ្សេប៉ាម ១ សំណាក = ១ %

### ២.៣. *ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ*

សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅក្នុងខែកញ្ញាឆ្នាំ២០១១នេះ សរុបមានចំនួន **៥.៨៥២.១២០** គ.ក្រ ដូចមានរាយមុខសារធាតុគីមីលំអិតនៅក្នុងតារាងឧបសម្ព័ន្ធ ។

## ៣. ការព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

ខែកញ្ញាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ជាសមាជិក រួមទាំងអង្គការជាតិ អន្តរជាតិ ដើម្បីបន្តយកចិត្តទុកដាក់លើការងារព្យាបាល មានដូចតទៅ :

### ៣.១. ការងារព្យាបាល ស្តារនីតិសម្បទា

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ**
  - តាមរយៈ អង្គការ អេហ្វ.អេច.អាយ FHI360 (អង្គការសុខភាពគ្រួសារអន្តរជាតិ) បានបោះពុម្ពលើកដំបូងនូវសៀវភៅ និង ខិត្តប័ណ្ណស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថមេតាដូន ជាភាសាខ្មែរ ។
  - បានចេញលិខិតណែនាំឱ្យមណ្ឌលបណ្តោះអាសន្នអប់រំ ព្យាបាល ស្តារនីតិសម្បទារបស់ រដ្ឋ និង ឯកជន អនុវត្តនូវកម្មវិធីប្រចាំថ្ងៃរបស់មណ្ឌល ។
  - បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងនិយាមបែបបទសម្រាប់ការអនុវត្តការបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន កាលពីថ្ងៃទី១៩ខែកញ្ញាឆ្នាំ២០១១ តាមការអញ្ជើញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ និយាមបែបបទនេះ មានជាប់ពាក់ពន្ធ័យ៉ាងច្រើនដល់ដំណើរការនៃការអនុវត្តកម្មវិធីថែទាំព្យាបាល អ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ (CBTx) ។ កិច្ចប្រជុំបានឯកភាព និងធ្វើការកែសម្រួលសេចក្តីព្រាងឯកសារនិយាមនេះ ព្រមទាំងជំរុញការបង្កើតឯកសារនិយាមសម្រាប់ (CBTx) ក្នុងពេលតែមួយ ដូច្នេះនៅពេលខាងមុខ កម្មវិធីសុខភាពផ្លូវចិត្ត និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល រួមជាមួយនឹងអង្គការដៃគូ នឹងរៀបចំបង្កើតឯកសារសំខាន់ចំនួនពីរគឺ :
    - ឯកសារនិយាមបែបបទសម្រាប់ការបង្ការ ថែទាំ និង ព្យាបាលបន្តចំពោះក្រុមអ្នកប្រើគ្រឿងញៀន ដែលផ្ទុកមេរោគអេដស៍ (សម្រាប់ការអនុវត្តដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) ។
    - ឯកសារនិយាមបែបបទ សម្រាប់ការបន្សាបថែទាំ និងព្យាបាលអ្នកញៀនគ្រឿងញៀនតាមមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ដែលត្រូវបានជ្រើសរើសសម្រាប់ផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ។
  - បានចាត់មន្ត្រីសម្របសម្រួលគម្រោង (Treatnet) ទៅចូលរួមតាមដាន ត្រួតពិនិត្យការងារ នៅខេត្តបន្ទាយមានជ័យ ពីថ្ងៃទី ២១-២៣ខែកញ្ញាឆ្នាំ២០១១ តាមការអញ្ជើញរបស់អង្គការUNODC ដើម្បីពិភាក្សាជាមួយអ្នកអនុវត្តកម្មវិធី និងអ្នកពាក់ពន្ធ័ដទៃទៀត ស្តីពីការអនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ។
- **ក្រសួងសុខាភិបាល** បានរៀបចំផែនការ៥ឆ្នាំ សម្រាប់អភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ហើយអាជ្ញាធរជាតិបានឯកភាពដាក់បញ្ចូលផែនការនេះ ទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ៥ ឆ្នាំ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានចេញប្រកាសលេខ ២០៨៣ ស.អ.យ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ស្តីពីការបិទដំណើរការមជ្ឈមណ្ឌលស្តារនីតិសម្បទាជីវិតថ្មី ស្មាច់មានជ័យ ខេត្តកោះកុង ។

### ៣.២. ការកាត់បន្ថយគ្រោះថ្នាក់

*អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ០១ រូប បានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាជាផ្លូវការ លើផែនការគាំទ្ររបស់អង្គការសហប្រជាជាតិសម្រាប់ប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។
- បានជួបពិភាក្សាការងារជាមួយប្រតិភូអង្គការ AusAID ប្រចាំនៅកម្ពុជាកាលពីថ្ងៃទី៣១ខែសីហាឆ្នាំ២០១១ ។ នៅក្នុងជំនួបពិភាក្សាការងារនេះ ភាគីទាំងពីរបានពិនិត្យពិភាក្សាទៅលើ **ទី១.** ការកែសម្រួលសមាសភាព **គណៈកម្មាធិការតម្រង់ទិស** របស់គម្រោង HAARP ដើម្បីឱ្យស្របតាមសភាពការណ៍បច្ចុប្បន្ន ។ **ទី២.** តាមរយៈលទ្ធផលនៃការវាយតម្លៃ ឯករាជ្យបានបង្ហាញឱ្យឃើញថា ការងារគ្រឿងញៀន/អេដស៍ និងការងាររបស់កម្មវិធី HAARP គឺមានចំណុចរួមគ្នា ដែលនឹងស្នើឱ្យមន្ត្រីជំនាញរបស់លេខាធិការដ្ឋានគ្រឿងញៀន/អេដស៍ និងលេខាធិការដ្ឋាននៃគម្រោង HAARP រួមគ្នាសិក្សាឱ្យបានស៊ីជម្រៅអំពីគុណសម្បត្តិនិងគុណវិបត្តិ នៃការរួមបញ្ចូលគ្នានេះ ដើម្បីមានវិធានការបានសមស្របក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជាកាន់តែទទួលបាននូវប្រសិទ្ធភាព ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែសីហា ឆ្នាំ ២០១១ កាលពីថ្ងៃទី០២/៩/២០១១ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- បានចាត់មន្ត្រីនាយកដ្ឋានជំនាញ ៤ រូប ឱ្យចុះទៅពិនិត្យជាក់ស្តែងនៅតំបន់ដែលអង្គការ **កសាង** ធ្លាប់បានធ្វើអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង និងធ្វើការស្ទាបស្ទង់មតិអាជ្ញាធរមូលដ្ឋាន ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ប្រទេសក្នុងអនុតំបន់ តំបន់ និង បណ្តាអង្គការជាដៃគូជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់សមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ ដូចតទៅ :

- បានសហការជាមួយអង្គការ អេហ្វ.អេច.អាយ FHI360 (អង្គការសុខភាពគ្រួសារអន្តរជាតិ) ក្រោមជំនួយថវិការបស់អង្គការ AusAID បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធ-ភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន (ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី ០១-០៥/៨/២០១១ មានសិក្ខាកាមជាគ្រូបង្គោលចំនួន ១៩ នាក់) ដោយមានគ្រូឧទ្ទេសនាមមកពីគម្រោង HAA-RP ប្រចាំតំបន់អាស៊ី, វេជ្ជបណ្ឌិតមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, អគ្គស្នងការដ្ឋាននគរបាលជាតិ, បណ្ឌិត្យសភាននគរបាលជាតិ ក្រសួងមហាផ្ទៃ, អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

- បានបន្តកិច្ចសហការជាមួយអង្គការ UNODC (កិច្ចការបន្តពីខែសីហាឆ្នាំ២០១១) ក្នុងការចុះទៅពិនិត្យភូមិសាស្ត្រដើម្បីបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) នៅខេត្តកំពត ។ ផ្តើមចេញពីកិច្ចប្រជុំមួយដែលមានការចូលរួមពីថ្នាក់ដឹកនាំខេត្តកំពត, តំណាងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ របស់ក្រសួងការពារជាតិ អង្គប្រជុំបានឯកភាព :
  - ស្នើសុំដាក់បញ្ចូលគម្រោងស្តីពីការបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ ទៅក្នុងកិច្ចប្រជុំត្រីភាគីថ្នាក់រដ្ឋមន្ត្រី (កម្ពុជា-វៀតណាម-ឡាវ) និងកិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រី (កម្ពុជា-វៀតណាម) ដើម្បីស្នើសុំការគាំទ្រ ។
  - ស្នើសុំបន្តកិច្ចសហការជាមួយអង្គការ UNODC (គម្រោង PATROL) រហូតដល់ការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន បានដំណើរការចប់សព្វគ្រប់ ។
  - ស្នើសុំបន្តសហការជាមួយអគ្គលេខាធិការដ្ឋានជាតិសន្តិសុខលម្ហសមុទ្រ ដើម្បីរៀបចំគោលការណ៍ និងបទដ្ឋាននានា ទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ ។
  - ស្នើសុំបន្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសវៀតណាម និងប្រទេសថៃ លើការងារទប់ស្កាត់បទល្មើសគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនលើលម្ហសមុទ្រ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ក៏ដូចជាបណ្តាអង្គការជាដៃគូអភិវឌ្ឍន៍នានា ដូចមានសកម្មភាពខាងក្រោម :

➢ ***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន :*

- បានជួបពិភាក្សាការងារជាមួយប្រតិភូអង្គការAusAID ប្រចាំនៅកម្ពុជា នាថ្ងៃទី៣១ខែសីហាឆ្នាំ២០១១ ។
- បានចូលរួមប្រជុំត្រៀមសម្រាប់កិច្ចប្រជុំ "ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន (ក.ស.វ.អ)" កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ បញ្ហាពាក់ព័ន្ធជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មាននៅចំណុច "**B6. ការធានាអាស៊ានមួយដែលគ្មានគ្រឿងញៀន**" ក្នុងទិសដៅយុទ្ធសាស្ត្រ "ការកាត់បន្ថយការរីករាលដាលនៃការប្រើបំពានគ្រឿងញៀនខុសច្បាប់នៅក្នុងចំណោមប្រជាពលរដ្ឋទូទៅ ពិសេស សិស្ស យុវជន និងក្រុមដែលងាយរងគ្រោះ តាមរយៈវិធានការបង្ការទប់ស្កាត់ និងការលើកកម្ពស់ឱ្យមានសេវាព្យាបាល ស្តារនីតិសម្បទា និងការថែទាំ ដើម្បីសមាហរណកម្មអ្នកទាំងនោះ ទៅក្នុងសង្គមវិញ តាមរយៈការលើកកម្ពស់នូវកិច្ចសហការជាមួយដៃគូរវាងផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលនានា ។
- បានបញ្ជូនឈ្មោះមន្ត្រីទំនាក់ទំនង ក្នុងការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ (Drug Control Fo- cal Points) ដើម្បីផ្ញើទៅលេខាធិការដ្ឋានរបស់សន្និសីទស្តីពីអន្តរសកម្មភាពនិងវិធានការកសាងទំនុកចិត្តនៅអាស៊ី(CICA) ។
- បានរៀបចំឯកសារជំនួយស្មារតីស្តីពីការងារអនុវត្តច្បាប់ ដើម្បីផ្ញើទៅក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ

(ONCB) ក្នុងនាម ONCB ជាប្រធាននៃកិច្ចប្រជុំក្រុមការងារអនុវត្តច្បាប់ និងរៀបចំឯកសារស្តីពីការងារអប់រំបង្ការផ្ញើទៅប្រទេសឥណ្ឌូនេស៊ី ក្នុងនាមប្រទេសឥណ្ឌូនេស៊ីជាប្រធានក្រុមការងារអប់រំបង្ការ សម្រាប់កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ ខ្ពស់អាស៊ានស្តីពីបញ្ហាគ្រឿងញៀន (ASOD) លើកទី៣២ ។

➢ ***នៅក្រៅប្រទេស***

- **គណៈប្រតិភូជាន់ខ្ពស់ ដែលដឹកនាំដោយឯកឧត្តម គៅ ខុនដារ៉ា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញទៅទស្សនកិច្ចនៅសហពន្ធ័រុស្ស៊ី កាលពីថ្ងៃទី ១៨-២៤/៩/២០១១ ។ កិច្ចប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់ និងពិនិត្យរួមគ្នាលើការអនុវត្តស្មារតីកំណត់ហេតុនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កម្ពុជា-រុស្ស៊ី ដែលបានចុះហត្ថលេខាតាំងពីថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៥ ។
- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា** បានប្រជុំជាមួយក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយបានចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះ ស្តីពីកិច្ចសហ-ប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រនិងបច្ចេកទេស កាលពីថ្ងៃទី២៣ខែសីហាឆ្នាំ២០១១ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។ នៅក្នុងកំណត់ហេតុ មានលើកអំពីកិច្ចសហប្រតិបត្តិការលើវិស័យត្រួតពិនិត្យគ្រឿងញៀន និង ការកសាងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលភាគីកម្ពុជាបានស្នើសុំការគាំទ្រពីភាគីវៀតណាម ។
- **អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានដឹកនាំគណៈប្រតិភូទៅចូលរួមប្រជុំទ្វេភាគីកម្ពុជា-ចិន លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅសាធារណរដ្ឋប្រជាមានិតចិន ( ថ្ងៃទី ០៥-០៩ ខែកញ្ញា ឆ្នាំ២០១១) ។ រាល់សំណើពហុវិស័យដែលពាក់ពន្ធ័នឹងការត្រួតពិនិត្យគ្រឿងញៀន និងបញ្ហាផ្សេងៗ ដែលបានស្នើសុំទៅវិញទៅមក ដោយភាគីកម្ពុជា-ចិន ត្រូវបានចុះហត្ថលេខាលើកំណត់ហេតុស្តីពី កិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅពីការអនុវត្តសកម្មភាពពហុវិស័យខាងលើ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំអនុវត្តសម្រេចនូវសកម្មភាពមួយចំនួនទៀត ដូចខាងក្រោម :

**១.** បានបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទៅស្ថាប័ននីតិប្បញ្ញត្តិដើម្បីស្នើសុំការអនុម័ត ។

**២.** បានរៀបចំសិក្ខាសាលា ពិគ្រោះយោបល់ជាមួយដៃគូពាក់ពន្ធ័ស្តីពីប្រសិទ្ធភាពក្នុងការផ្តល់សេវារបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន នាថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០១១ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានសមាសភាពចូលរួមមកពីក្រសួងមហាផ្ទៃ, ក្រសួងផែនការ, ក្រសួងសុខាភិបាល, ក្រសួងសង្គមកិច្ច(ស.អ.យ), ក្រសួងអប់រំយុវជន និងកីឡា, អង្គការមិត្តសម្លាញ់, អង្គការមិត្តសម្លាញ់អន្តរជាតិ(FI), អង្គការCCJAP, UNICEF, FHI, USAID, WHO, UNAID, UNODC, AusAID, UNDP, UNESCO, សមាគមយុវជនខ្មែរ, អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មណ្ឌលព័ត៌មានស្ត្រីកម្ពុជា សរុបចំនួន ៤៦ នាក់ ។

**៣.** បានបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នជាសមាជិក ជាពិសេស ក្រសួងមហាផ្ទៃ ដើម្បីបន្តកិច្ចការរៀបចំគណៈ

កម្មការចម្រុះជួយដោះស្រាយបញ្ហាគ្រឿងញៀន នៅបណ្តាខេត្តភាគពាយ័ព្យសាធនប្រទេស ។

៤. បានចុះធ្វើការសិក្សាបឋមនៅក្នុង រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និង ខេត្តស្វាយរៀង ដើម្បីប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀន និងឥរិយាបថគ្រោះថ្នាក់របស់ពួកគេ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ក្នុងខែកញ្ញាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការចូលរួមពីក្រសួង-ស្ថាប័នជាសមាជិក ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការជាតិ-អន្តរជាតិនានា បានអនុវត្តតាមទិសដៅសកម្មភាពពហុវិស័យ ដែលបានដាក់ចេញកាលពីខែសីហាកន្លងទៅ ទទួលបានលទ្ធផលល្អប្រសើរ ។ ទន្ទឹមនឹងគុណសម្បត្តិនេះ យើងចាំបាច់ត្រូវតែបន្តរិះរកដំណោះស្រាយជាបន្ទាន់ចំពោះ **បញ្ហាប្រឈម** ជាអាទិ៍ ការប្រឈមនឹងកង្វះខាតទីកន្លែងសម្រាប់ទទួលអ្នកញៀនពីខាងក្រៅ ដែលសមត្ថកិច្ចបានចាប់បញ្ជូនមកប្រគល់ឱ្យមណ្ឌលបណ្តោះអាសន្ន នៅពេលអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" និង **ចំណុចខ្វះខាត** មួយចំនួន ដូចជា វិធានការដោះស្រាយចំពោះការលបលួចប្រើប្រាស់គ្រឿងញៀនដោយ ទណ្ឌិត និង ពិរុទ្ធជន នៅតាមមណ្ឌលអប់រំកែប្រែ និង ពន្ធនាគារ ជាដើម ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែតុលា ឆ្នាំ២០១១

ដើម្បីឈានទៅសម្រេចទិសដៅសកម្មភាពពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន នឹងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តស្ទឹងត្រែង ដើម្បីផ្តល់កិច្ចសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ CTN ក្រោមប្រធានបទស្តីពី ការទទួលការខុសត្រូវក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់ខេត្តស្ទឹងត្រែង (សប្តាហ៍ចុងខែតុលា) ។

១.២. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយក្រសួងជាសមាជិកអាជ្ញាធរជាតិ ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងអង្គការជាតិ-អន្តរជាតិ ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ ដឹងជាសាធារណៈ ពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ដើម្បីចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហឹង្សា ។

១.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីផលិតបន្ថែមនូវប័ណ្ណផ្សព្វផ្សាយអប់រំពី គ្រឿងញៀន អេដស៍ ការជួញដូរភេទ និង ការជួញដូរអាវុធជាតិផ្ទុះ ។

១.៤. អគ្គលេខាធិការដ្ឋាន នឹងសម្របសម្រួលជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំសិស្សានុសិស្ស នៅក្នុង **សារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសបើកបវេសនកាល ឆ្នាំសិក្សា ២០១១-២០១២ នាថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១១ ។

១.៥. ត្រៀមរៀបចំពិព័រណ៍រូបភាព សម្រាប់បុណ្យខួប ២០ ឆ្នាំ នៃការយាងនិវត្តន៍មកកាន់មាតុប្រទេស របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ និង ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មថ្វាយព្រះអង្គគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា, ទិវាបុណ្យ ឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ។

១.៦. បន្តជំរុញការរៀបចំសាលាបែតង ដើម្បីផ្សព្វផ្សាយ និងអនុវត្តនៅឆ្នាំ២០១២ ខាងមុខ ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត (ជាពិសេសខេត្តនៅតាមព្រំដែន) ដើម្បីពង្រឹងលើការងារត្រួតពិនិត្យបទល្មើសគ្រឿងញៀន និងសារធាតុគីមីផ្សំ ទាំងនៅតាមបណ្តាច្រកព្រំដែនអន្តរជាតិ ច្រកទ្វេភាគី និងច្រករបៀង ព្រមទាំងបន្តជំរុញកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅក្នុងប្រទេស ទាំងករណីធំៗ និងករណីតូចតាច ។

២.២. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយអង្គការUNODC បន្តធ្វើការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) ។

២.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តសហការជាមួយក្រសួង-ស្ថាបន័ពាក់ពន្ធ័ ដើម្បីប្រមូលទិន្នន័យ ស្តីពី ការនាំចូល នាំចេញ និង ការប្រើប្រាស់សារធាតុគីមីផ្សំ ។

២.៤. អគ្គលេខាធិការដ្ឋាន ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាពីលទ្ធផលបឋមពាក់ពន្ធ័ដំណើរការសិក្សា និងប្រមូលព័ត៌មាន លើការងារត្រួតពិនិត្យនិងគ្រប់គ្រងសារធាតុគីមីផ្សំនៅខេត្តស្វាយរៀង និង ខេត្តកណ្តាល ។

២.៥. អគ្គលេខាធិការដ្ឋាន នឹងបន្តអនុវត្តវិធានការដោះស្រាយបញ្ហាទណ្ឌិត និងពិរុទ្ធជន នៅក្នុងពន្ធនាគារដែលបានលបលួចប្រើប្រាស់គ្រឿងញៀន ។

២.៦. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បី ជំរុញការស៊ើបអង្កេត ស្រាវជ្រាវករណីប្រេងម្រះព្រៅភ្នំដែលខេត្តកំពង់ឆ្នាំង ចាប់កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១ចំនួន ៦០០ លីត្រ និង ១២៣ គ.ក្រ ។

២.៧. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីបន្តការតាមដានស្រាវជ្រាវស៊ើបអង្កេត ករណីនាំប្រាក់ដុល្លារចំនួន ២០៩.៩០០ ដុល្លារ ចេញទៅប្រទេសឡាវ កាលពីថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០១១ និងសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីជំរុញដំណើរការក្នុងការអនុវត្តតាមនីតិវិធីច្បាប់ឱ្យមានប្រសិទ្ធភាព ។

## ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ដើម្បីតាមដានសំណើសុំ

ជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ស្នើសុំទៅភាគីវៀតណាម តាមរយៈកិច្ចប្រជុំគណៈកម្មការចម្រុះទ្វេភាគី កម្ពុជា-វៀតណាម លើកទី១២ ។

៣.២. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានការអនុវត្ត កម្មវិធីប្រចាំថ្ងៃនៅតាមមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាបព្យាបាល និងស្តារនីតិសម្បទាអ្នកញៀន គ្រឿងញៀនរបស់រដ្ឋនិងឯកជន ។

៣.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តធ្វើការសម្របសម្រួលជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីបង្កើនល្បឿននៃការរៀបចំការអនុវត្តនូវការផ្តល់សេវាព្យាបាលតាមសហគមន៍ លើគោលដៅ ២០% នៃឃុំ-សង្កាត់ គោលដៅ ។

៣.៤. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីធ្វើការវាយតម្លៃអំពីការអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថមេតាដូន ។

៣.៥. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជំរុញការកែសម្រួល គោលនយោបាយស្តីពីកម្មវិធីប្តូរម្ជុល/ស៊ីរ៉ាំង ដើម្បីអនុវត្តឱ្យបានសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

៤.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធនានា ដើម្បីជំរុញការស្នើសុំបង្កើតគណៈកម្មការចម្រុះដោះបញ្ហាគ្រឿងញៀនខេត្តនៅតាមព្រំដែនភាគឦសាន ។

៤.២. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយអង្គការដៃគូអភិវឌ្ឍន៍ គណៈកម្មាធិការត្រួតពិនិត្យខេត្ត ដែលមិនទាន់បានបណ្តុះបណ្តាល ដើម្បីបន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ ។

៤.៣. អគ្គលេខាធិការដ្ឋាន នឹងរៀបចំកិច្ចប្រជុំមួយដើម្បីវាយតម្លៃលទ្ធផលការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន ក្នុងគោលដៅកែសម្រួលឡើងវិញអំពីតួនាទី និងភារកិច្ចរបស់ការិយាល័យនេះ (BLO) ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. អគ្គលេខាធិការដ្ឋាន នឹងត្រៀមលក្ខណៈចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន លើកទី៣២ (**A**SEAN **S**enior **O**fficials on **D**rug Matters. ASOD) ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ (១០-១២/១០/២០១១) ។

៥.២. អគ្គលេខាធិការដ្ឋាន នឹងត្រៀមរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន តាមស្មារតីប្រជុំត្រៀមសម្រាប់កិច្ចប្រជុំ "ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន" (ក.ស.វ.អ) ដែលអគ្គលេខាធិការដ្ឋាន បានទៅចូលរួមប្រជុំកាលពីថ្ងៃទី១២/៩/២០១១ ។

៥.៣. អគ្គលេខាធិការដ្ឋាន នឹងត្រៀមខ្លឹមសារផ្តល់យោបល់ លើពង្រាងរបាយការណ៍ចុងក្រោយ ស្តីពីការវាយ

តម្លៃនៃការហូរចូលនូវថវិកាខុសច្បាប់ ដែលបានមកពីជំនួញគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត ផ្ញើទៅការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ ។

៥.៤. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងត្រៀមរៀបចំឯកសារច្បាប់ បទប្បញ្ញត្តិនានា និងបំពេញក្នុងតារាងដែលបានណែនាំមួយចំនួនពាក់ពន្ធ័នឹងការត្រួតពិនិត្យការនាំចេញ-នាំចូលដែលបានអនុវត្តនៅក្នុងប្រទេស ទៅក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អ.ស.ប ។

៥.៥. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងត្រៀមទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការប្រមូលទិន្នន័យ ការវិភាគ និងរបាយការណ៍សម្រាប់គោលនយោបាយ និងសកម្មភាព (១៨-២១ ខែតុលា ឆ្នាំ២០១១) នៅទីក្រុងបាងកក ប្រទេសថៃ ។

ក្រៅពីទិសដៅសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារចំពោះមុខមួយចំនួនទៀត ដូចជា :

- បន្តការតាមដាន និងសហការជាមួយស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ស្នើសុំការអនុម័ត ។
- បន្តជំរុញការរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ដល់មន្ត្រីលេខាធិការដ្ឋានគ្រឿងញៀន/អេជស៍រាជធានី-ខេត្ត ក្នុងការប្រើប្រាស់ប្រពន្ធ័កម្មវិធីបញ្ចូលទិន្នន័យ តាមផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀនដើម្បីមន្ត្រីលេខាធិការដ្ឋានអាចបញ្ចូលទិន្នន័យទៅក្នុងកម្មវិធីដោយខ្លួនឯង ។
- ត្រៀមបោះពុម្ពសៀវភៅណែនាំការប្រើប្រាស់កម្មវិធីគ្រប់គ្រងទិន្នន័យ ដើម្បីចែកជូនលេខាធិការដ្ឋានគ្រឿងញៀន/អេដស៍ រាជធានី-ខេត្ត ។
- ការរៀបចំគម្រោងស្តីពីការអភិវឌ្ឍដំណាំជំនួសដើមម្រះព្រៅភ្នំ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អជបគញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

# សកម្មភាពសំខាន់ៗក្នុងការដឹកនាំ
# អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១១

| ល.រ | ខ្លឹមសារ និង គោលដៅ |
|---|---|
| ១ | បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅទស្សនកិច្ចនៅសហពន្ធ័រុស្ស៊ី ១៧-២៤/៩/២០១១ |
| ២ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមប្រជុំគុមូលប្រចាំឆ្នាំក្នុងន័យដើម្បីបំផុសចលនាអគ្គកេម្មឲ្យបានជ្រួតជ្រាបគ្រប់ក្រសួង ស្ថាបន័រដ្ឋ និងឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ក្រោមប្រធានបទ អគ្គកេម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន |
| ៣ | បានអនុញ្ញាតឲ្យគណៈប្រតិភូរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមប្រជុំទ្វេភាគី កម្ពុជា- ចិន លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការ ត្រួតពិនិត្យគ្រឿងញៀន នៅសាធារណរដ្ឋប្រជាមានិតចិន ០៥-០៩/៩/២០១១ |
| ៤ | បានណែនាំឲ្យរៀបចំដាក់បញ្ចូលនូវ ផែនការអភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ៥ឆ្នាំ របស់ក្រសួងសុខាភិបាល ទៅក្នុងផែនការយុទ្ធសាស្ត្រជាតិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| ៥ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ផ្តល់ឈ្មោះមន្ត្រីទំនាក់ទំនង ក្នុងការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ (Drug Control Focal Point ) ទៅលេខាធិការដ្ឋានរបស់សន្និសីទស្តីពីអន្តរសកម្មភាព និងវិធានការកសាងទំនុកចិត្តនៅអាស៊ី (CICA) |
| ៦ | បានបញ្ជូនរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ទៅក្រសួងផែនការ |
| ៧ | បានណែនាំឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត រៀបចំឲ្យមានកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ របស់ខ្លួន |
| ៨ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន ទៅចូលរួមនៅក្នុងពិធីចុះហត្ថលេខាលើ ផែនការគាំទ្ររបស់អង្គការសហប្រជាជាតិសម្រាប់ប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា |
| ៩ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន សហការជាមួយ អគ្គស្នងការដ្ឋាននគរបាលជាតិ បន្តការតាមដាន ស្រាវជ្រាវ ករណីនាំប្រាក់ដុល្លារ ចំនួន ២០៩.៩០០ ដុល្លារ ទៅប្រទេសឡាវ កាលពីថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ និងសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីជំរុញដំណើរការអនុវត្តតាមនីតិវិធីច្បាប់ឲ្យមានប្រសិទ្ធភាព |
| ១០ | ការណែនាំឲ្យក្រសួងសុខាភិបាល រៀបចំឯកសារនិយាមបែបបទសម្រាប់បង្ការ ថែទាំនិងព្យាបាលបន្ត ចំពោះក្រុមអ្នកប្រើគ្រឿងញៀនដែលផ្ទុកមេរោគអេដស៍ និងឯកសារនិយាមបែបបទសម្រាប់ការបន្សាបថែទាំ និងព្យាបាលអ្នកញៀនគ្រឿងញៀនតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលត្រូវជ្រើសរើសសម្រាប់ផ្តល់សេវាព្យាបាលដោយផ្អែកលើសហគមន៍ |

## សកម្មភាពផ្សព្វផ្សាយអប់រំ ប្រចាំខែ កញ្ញា ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាបន័ | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | -បានចូលរួមប្រជុំគុមូលនៅក្រសួងអប់រំយុវជន និងកីឡា តាមការអញ្ជើញរបស់ក្រសួង កាលពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១១ ក្នុងន័យបំផុសចលនាអគ្គកេម្មឲ្យបានជ្រួតជ្រាបគ្រប់ក្រសួង-ស្ថាប័នរដ្ឋ និងឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ក្រោមប្រធានបទស្តីពី " អគ្គកេម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន "<br>-បានសម្របសម្រួលជាមួយស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន ម៉ាយធីវី ដើម្បីបង្កើនការផ្សព្វផ្សាយឲ្យបានកាន់តែច្រើនថែមទៀតនូវបទចម្រៀងទាំងឡាយណា ដែលមានបង្កប់អត្ថន័យអប់រំដល់យុវជនកុំឲ្យប្រើគ្រឿងញៀន<br>-បានផ្តល់ផ្ទាំងរូបភាព ច្បាប់ និងឯកសារផ្សព្វផ្សាយមួយចំនួនដល់ ខេត្តកំពង់ចាមដើម្បីបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ សិស្សានុសិស្ស នៅតាមស្រុក-ក្រុង ទាំង១៧<br>-តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមក្នុងកិច្ចប្រជុំអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន( ១៤/៩/២០១១ អ្នកចូលរួម ៤០ នាក់) | ៤០ នាក់ |
| ២ | ក្រចេះ | -ស្នងការដ្ឋាននគរបាលខេត្តក្រចេះ បានចុះផ្សព្វផ្សាយ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋនៅស្រុកឆ្លូង ចំនួន <u>៣៥</u> នាក់ / ស្រី ៧ នាក់<br>-អាជ្ញាធរក្រុងក្រចេះ បានចុះផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន និងបញ្ហាអេដស៍ ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ គ្រូបង្គោល និងព្រះសង្ឃនៅតាមវត្តអារាម ( សប្តាហ៍ទី១ ចំនួន <u>១២០</u> នាក់ / ស្រី ៥៣ នាក់, សប្តាហ៍ទី២ ចំនួន <u>១៤២</u> នាក់ / ស្រី ៥៣ នាក់ ) | ២៩៧ នាក់ |
| ៣ | ប៉ៃលិន | -លេខាធិការដ្ឋានគ្រឿងញៀនខេត្តប៉ៃលិន សហការជាមួយ CHED ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ចំនួន<u>១៦៦</u> នាក់ | ១៦៦ នាក់ |
| ៤ | ព្រះវិហារ | -អាជ្ញាធរក្រុងព្រះវិហារ ស្រុកគូលែន ស្រុកសង្គមថ្មី ស្រុករវៀង ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង | ១.៨៩៤ នាក់ |

| | | | |
|---|---|---|---|
| | | ញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងឱកាសផ្សព្វផ្សាយពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព (សប្តាហ៍ទី២ ចំនួន ១១ លើក = **១.៨៩៤** នាក់ / ស្រី ៧៤៣ នាក់) | |
| ៥ | កំពង់ធំ | -អាជ្ញាធរស្រុកប្រាសាទសំបូរ បានចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅឃុំឈូក និង ឃុំគោល ដល់ប្រជាពលរដ្ឋ **៤៣** នាក់ / ស្រី ១៦ នាក់<br>-អាជ្ញាធរស្រុកប្រាសាទបល្ល័ង្គ បានចុះផ្សព្វផ្សាយ បានចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅឃុះសាលាវិស័យ ឃុះទូលគ្រើល ឃុះក្រយា និងឃុះសាគ្រាម ដល់ប្រជាពលរដ្ឋ ចំនួន **៧២៨** នាក់ / ស្រី ៣៤២ នាក់<br>-អាជ្ញាធរស្រុកបារាយណ៍ ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅឃុំបាល័ង្គ និងឃុំបារាយណ៍ ដល់ប្រជាពលរដ្ឋចំនួន **១៩៣** នាក់ / ស្រី ៨៥ នាក់<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ដល់សិក្ខាកាមដែលកំពុងបណ្តុះបណ្តាលផ្នែកសេវាកម្ម និង និស្សិតថ្នាក់បរិញ្ញាបត្រង ចំនួន **២២០** នាក់ / ស្រី ១១៧ នាក់ | ១.១៨៤ នាក់ |
| ៦ | តាកែវ | -អាជ្ញាធរក្រុងដូនកែវ និង ស្រុកបុរីជលសារ ផ្សព្វផ្សាយអំពីផលប៉ះពាល់នៃគ្រឿងញៀន (សប្តាហ៍ទី១ ចំនួន ៤ លើក = **២១៣** នាក់ / ស្រី ១១១ នាក់) | ២១៣ នាក់ |
| ៧ | បាត់ដំបង | -នគរបាលស្រុកថ្មគោល ផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ (សប្តាហ៍ទី ៤ ចំនួន ២ លើក = **៣៧៨** នាក់ / ស្រី ១០២ នាក់) | ៣៧៨ នាក់ |
| ៨ | សមា.នារីកម្ពុ.ដ៏.សន្តិ.អភិ. | -បានចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន អេដស៍ សុខភាពបន្តពូជ និងកាមរោគ នៅតាមកាស៊ីណូ ផ្ទះសំណាក់ កន្លែងខារាអូខេ និង កន្លែងកំសាន្តសប្បាយក្នុងក្រុងប៉ៃលិន មានអ្នកចូលរួម **២៦៩** នាក់ | ២៦៩ នាក់ |
| | | សរុប | **៤.៤៤១ នាក់** |

## បទល្មើសគ្រឿងញៀនដែលបង្ក្រាប ក្នុងខែ កញ្ញា ឆ្នាំ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ដឹកជញ្ជូន ជួញដូរ | | | ផលិត | | | ដាំដុះ ចម្រាញ់ប្រេងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **7** | **21** | **5** | 7 | 19 | 4 | | | | | | | | | | 0 | 2 | 1 |
| 2 | ន.ប ភ្នំពេញ | **15** | **37** | **6** | 13 | 34 | 5 | | | | | | | 2 | 3 | 1 | | | |
| 3 | ន.ប កណ្តាល | **1** | **7** | **0** | 1 | 6 | 0 | | | | | | | | | | 0 | 1 | 0 |
| 4 | ន.ប កំពង់ស្ពឺ | **1** | **3** | **1** | 1 | 3 | 1 | | | | | | | | | | | | |
| 5 | ន.ប កំពង់ចាម | **2** | **6** | **0** | 2 | 3 | 0 | | | | | | | | | | 0 | 3 | 0 |
| 6 | ន.ប ព្រះសីហនុ | **1** | **1** | **0** | 1 | 1 | 0 | | | | | | | | | | | | |
| 7 | ន.ប សៀមរាប | **3** | **3** | **0** | 2 | 1 | 0 | | | | | | | 1 | 2 | 0 | | | |
| 8 | ន.ប ស្ទឹងត្រែង | **4** | **11** | **2** | 4 | 11 | 2 | | | | | | | | | | | | |
| 9 | ន.ប ព្រះវិហារ | **1** | **3** | **1** | 1 | 3 | 1 | | | | | | | | | | | | |
| 10 | ន.ប រតនគីរី | **2** | **7** | **1** | 2 | 7 | 1 | | | | | | | | | | | | |
| 11 | ន.ប បាត់ដំបង | **3** | **10** | **1** | 2 | 9 | 1 | | | | | | | 1 | 1 | 0 | | | |
| 12 | ន.ប បន្ទាយមានជ័យ | **7** | **17** | **4** | 7 | 17 | 4 | | | | | | | | | | | | |
| 13 | ន.ប កំពង់ធំ | **0** | **1** | **0** | | | | | | | | | | | | | 0 | 1 | 0 |
| 14 | ន.ប ក្រចេះ | **1** | **2** | **0** | 1 | 2 | 0 | | | | | | | | | | | | |
| 15 | ន.ប មណ្ឌលគីរី | **1** | **3** | **2** | 1 | 3 | 2 | | | | | | | | | | | | |
| 16 | ន.ប ប៉ៃលិន | **1** | **3** | **0** | 1 | 3 | 0 | | | | | | | | | | | | |
| | **សរុប** | **50** | **135** | **23** | **46** | 122 | 21 | | | | | | | **4** | 6 | 1 | **0** | 7 | 1 |

## វត្ថុតាងចាប់យក ប្រចាំខែ កញ្ញា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | **WY** (គ្រាប់) | **ICE** (ក្រាម) | **Heroine** (ក្រាម) | ដើមកញ្ឆា ម២ | កញ្ឆាក្រៀម (ក្រាម) | **Ecstasy** (គ្រាប់) | **Pseudo-Ephedrine** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| *1* | **មន្ទីរប្រឆាំងគ្រឿងញៀន** | *1.669* | *1.216,9* | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| *2* | ន.ប ភ្នំពេញ | | *9,89* | | | *14,46* | | | | |
| *3* | ន.ប កំពង់ស្ពឺ | | *0,36* | | | | | | | |
| *4* | ន.ប កំពង់ចាម | *4* | | | | | | | | |
| *5* | ន.ប ព្រះសីហនុ | | *1,3* | | | | | | | |
| *6* | ន.ប សៀមរាប | *2* | *9* | | | | | | | |
| *7* | ន.ប ស្ទឹងត្រែង | *1* | *2,20* | | | | | | | |
| *8* | ន.ប ព្រះវិហារ | *40* | *1,3* | | | | | | | |
| *9* | ន.ប រតនគីរី | *30* | *1,162* | | | | | | | |
| *10* | ន.ប បាត់ដំបង | *7* | | | | | | | | |
| *11* | ន.ប បន្ទាយមានជ័យ | *242* | *0,09* | | | | | | | |
| *12* | ន.ប ក្រចេះ | | *4,3* | | | | | | | |
| *13* | ន.ប មណ្ឌលគីរី | | *2,63* | | | | | | | |
| *14* | ន.ប ប៉ៃលិន | *5* | | | | | | | | |
| | សរុប | ***2.000*** | ***1.249,132*** | | | ***14,46*** | | | | |

## វត្ថុតាងផ្សេងៗ

-មន្ទីរប្រឆាំង គ្រ.ញ — Heroin ១ កញ្ចប់តូច, ម្សៅសង្ស័យគ្រឿងញៀន ៣៤៥ ក្រាម, រថយន្ត២, ម៉ូតូ៦, កុំព្យូទ័រ ១, លុយ ៧.២០០ រៀល, ២៣០ ដុល្លារ, ១៣៤.០០០ ដុង, លិខិតឆ្លងដែន ៣

-ន.ប ភ្នំពេញ — (ដុំក្រាមពណ៌ស សង្ស័យគ្រឿងញៀន ១៦៩,០៤ ក្រាម + ម្សៅពណ៌ស សង្ស័យគ្រឿងញៀន ៤០៤,៨៦ ក្រាម សរុប ៥៧៣,៩ ក្រាម), ជញ្ជីង ៥, ប្រាក់ដុល្លារក្លែងក្លាយប្រភេទក្រដាស ២០ ចំនួន ២ សន្លឹក, កាំភ្លើងខ្លី ១ ដើម + គ្រាប់ ៣០ គ្រាប់, កាមេរា ១, ម៉ូតូ ៧, រថយន្ត ១, កុំព្យូទ័រយួរដៃ ១, IPAD ១, វិទ្យុទាក់ទង ២, ប្រាក់ ៣១៥.០០០ រៀល, ១២១ ដុល្លារ, ៤០ បាត និង ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន

-ន.ប កណ្ដាល — សម្ភារៈប្រើប្រាស់មួយចំនួន

-ន.ប កំពង់ស្ពឺ — ម៉ូតូ ១

-ន.ប កំពង់ចាម — ឧបករណ៍ប្រើប្រាស់មួយចំនួន

-ន.ប ព្រះសីហនុ — ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់គ្រឿងញៀនមួយចំនួន

-ន.ប សៀមរាប — Ice ២ កញ្ចប់តូច, រថយន្ត ១, ប្រាក់ ៣.០០០.០០០ រៀល, ៣០០ ដុល្លារ និង ឧបករណ៍ប្រើគ្រឿងញៀនមួយចំនួន

-ន.ប ស្ទឹងត្រែង — ប្រាក់ ២០៩.៩០០ ដុល្លារ

-ន.ប រតនគីរី — ម៉ូតូ ១

-ន.ប បាត់ដំបង — WY កន្លះគ្រាប់, ម៉ូតូ ១, វិទ្យុទាក់ទង ២, ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន

-ន.ប បន្ទាយមានជ័យ — ម៉ូតូ ១, លុយក្លែងក្លាយ ប្រភេទក្រដាស៥០០ ចំនួន ៩ សន្លឹក

-ន.ប មណ្ឌលគីរី — លុយ ២៦៧.០០០ រៀល,

-ន.ប ប៉ៃលិន — ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន